# ព្រះរាជក្រម

នស/រកម/០៤១៧/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

## ស្តីពី

## វិសោធនកម្មច្បាប់ស្តីពី

## លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

មាត្រា ១ មាត្រា ៥ មាត្រា ៦ មាត្រា ៧ មាត្រា ៨ មាត្រា ៩ មាត្រា ១២ មាត្រា ១៣ មាត្រា ២០ មាត្រា ២១ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៦ មាត្រា ២៧ មាត្រា ៣២ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ មាត្រា ៣៦ មាត្រា ៥៦ មាត្រា ៦៥ និងមាត្រា ៧៣ នៃច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃ ទី១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម៖

**មាត្រា ១.- ថ្មី**

ច្បាប់នេះអនុវត្តចំពោះអ្នករាជការនៃក្រុមនីតិប្បញ្ញត្តិក្នុងក្របខ័ណ្ឌណាមួយដែលមានចែងក្នុងមាត្រា ៥ ថ្មី នៃច្បាប់នេះ ។

អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិមានអ្នករាជការក្របខ័ណ្ឌរដ្ឋនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

ច្បាប់នេះក៏អនុវត្តចំពោះអ្នករាជការក្របខ័ណ្ឌរដ្ឋនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញផងដែរ ។

**មាត្រា ៥.- ថ្មី**

ក្របខ័ណ្ឌរបស់អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិត្រូវបានបែងចែកជាបីប្រភេទគឺ ៖

១- **ប្រភេទ ក** - ក្របខ័ណ្ឌអភិបាល

២- **ប្រភេទ ខ** - ក្របខ័ណ្ឌឧបការី

៣- **ប្រភេទ គ** - ក្របខ័ណ្ឌលេខាធិការ ។

**មាត្រា ៦.- ថ្មី**

ក្របខ័ណ្ឌអភិបាលត្រូវបានបែងចែកជាបីឋានន្តរសក្តិដូចតទៅ ៖

១-ឋានន្តរសក្តិទី ១ ឧត្តមអភិបាល

២-ឋានន្តរសក្តិទី ២ វរអភិបាល

៣-ឋានន្តរសក្តិទី ៣ អភិបាល ។

**មាត្រា ៧.- ថ្មី**

ក្របខ័ណ្ឌឧបការីត្រូវបានបែងចែកជាបីឋានន្តរសក្តិដូចតទៅ ៖

១-ឋានន្តរសក្តិទី ១ នាយឧបការី

២-ឋានន្តរសក្តិទី ២ ឧបការីដើមខ្សែ

៣-ឋានន្តរសក្តិទី ៣ ឧបការី ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

**មាត្រា ៨.- ថ្មី**

ក្របខ័ណ្ឌលេខាធិការមានមួយឋានន្តរសក្តិ ។

**មាត្រា ៩.- ថ្មី**

ថ្នាក់ក្នុងឋានន្តរសក្តិនៃប្រភេទក្របខ័ណ្ឌ **ក** ក្របខ័ណ្ឌ **ខ** និងក្របខ័ណ្ឌ **គ** ត្រូវកំណត់ដោយសេចក្តីសម្រេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

**មាត្រា ១២.- ថ្មី**

អ្នករាជការក្នុងក្របខ័ណ្ឌលេខាធិការត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬបានចូលរួមវគ្គបណ្តុះបណ្តាលមុខវិជ្ជាជីវៈកម្រិតបឋមដោយមានវិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រ បញ្ជាក់ពីចំណេះបច្ចេកទេស ឬចំណេះធ្វើការងារជាក់លាក់ដែលជាតម្រូវការនៃស្ថាប័ន និងមានឧបនិស្ស័យសម្រាប់កាន់មុខតំណែងជាលេខាធិការក្នុងការិយាល័យ ។

**មាត្រា ១៣.- ថ្មី**

អ្នករាជការអាចប្តូរក្របខ័ណ្ឌខ្ពស់ជាងបានតាមរយៈការប្រឡងប្តូរប្រភេទក្របខ័ណ្ឌផ្ទៃក្នុង ដូចមានចែងក្នុងមាត្រា ៣១ នៃច្បាប់នេះ ។ល័ក្ខខ័ណ្ឌនិងបែបបទនៃការប្រឡងប្តូរប្រភេទក្របខ័ណ្ឌត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ។

**មាត្រា ២០.- ថ្មី**

ការប្រឡងចូលក្របខ័ណ្ឌណាមួយ ត្រូវរៀបចំដោយគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-អគ្គលេខាធិការ ឬតំណាង | ប្រធាន |
| ២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ | សមាជិក |
| ៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ | សមាជិក |
| ៥-អ្នករាជការពីររូបក្នុងក្របខ័ណ្ឌជាមួយ | សមាជិក ។ |

**មាត្រា ២១.- ថ្មី**

ការប្រឡងចូលក្របខ័ណ្ឌ នៃឋានន្តរសក្តិ ថ្នាក់ដំបូង ៖

- អភិបាល បេក្ខជនដែលមានសញ្ញាប័ត្រកម្រិតអប្បរមា បរិញ្ញាប័ត្រ ឬសញ្ញាប័ត្រមានតម្លៃស្មើ ។

-ឧបការី បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិបូកវគ្គបណ្តុះបណ្តាលរយៈពេល ២ ឆ្នាំ ដោយមានវិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រ។

-លេខាធិការ បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬបានចូលរួមវគ្គបណ្តុះបណ្តាលមុខវិជ្ជាជីវៈកម្រិតបឋមដោយមានវិញ្ញាបនប័ត្រ ឬសញ្ញាប័ត្រ ។

## មាត្រា ២៣.– ថ្មី

រយៈពេលកម្មសិក្សាត្រូវកម្រិត ១២ ខែ ដោយត្រូវគិតតាំងពីថ្ងៃតែងតាំងកម្មសិក្សាការីនោះ ។

កម្មសិក្សានេះមិនត្រូវយកជាការបានទេ បើកាលណាសាមីជនខកខានពុំបានមកធ្វើកម្មសិក្សាសរុប ៣០ ថ្ងៃ។ ក្នុងករណីនេះ សាមីជនត្រូវបន្តធ្វើកម្មសិក្សានៅលើកទី ២ ទៀត។ ការបន្តធ្វើកម្មសិក្សាជាលើកទី ២ ត្រូវមានរយៈពេលស្មើនឹងរយៈពេលលើកទី ១ ដែរ ។

អ្នករាជការក្របខ័ណ្ឌចាស់ ដែលបានប្រឡងជាប់ទៅកាន់ក្របខ័ណ្ឌខ្ពស់ជាង មិនចាំបាច់ធ្វើកម្មសិក្សាឡើយ ។

## មាត្រា ២៤.– ថ្មី

ការតាំងស៊ប់ត្រូវតែសម្រេចក្នុងរយៈពេលមិនលើសពី ៣ ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលកម្មសិក្សា ។

ការតាំងស៊ប់ចាប់ផ្តើមមានប្រសិទ្ធភាពខាងផ្នែកបៀវត្សក៏ដូចជាអតីតភាពការងារសម្រាប់ឡើងថ្នាក់ ។ប៉ុន្តែអតីតភាពការងារសម្រាប់ចូលនិវត្តន៍ត្រូវបានគិតបញ្ចូលតាំងពីពេលចាប់ផ្តើមធ្វើកម្មសិក្សា ។

ការតាំងស៊ប់ត្រូវសម្រេចដោយប្រធានស្ថាប័នតាមសេចក្តីស្នើរបស់អគ្គលេខាធិការ ក្រោយពីមានការផ្តល់យោបល់ពីគណៈកម្មការមួយដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| ១-អគ្គលេខាធិការ ឬតំណាង | ប្រធាន |
| ២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ | សមាជិក |
| ៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ | សមាជិក |
| ៥-អ្នករាជការ ២រូបដែលមានក្របខ័ណ្ឌដូចគ្នា | សមាជិក ។ |

## មាត្រា ២៦.– ថ្មី

បៀវត្សរបស់កម្មសិក្សាការីត្រូវបានកាត់ទុកសម្រាប់ប្រាក់សោធននិវត្តន៍។ បើសិនជាកម្មសិក្សាការីមិនត្រូវបានតាំងស៊ប់ទេនោះ ប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍នោះត្រូវបានបង្វិល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

សងសាមីជនវិញទាំងអស់។

ក្នុងរយៈពេលកម្មសិក្សានេះ កម្មសិក្សាការីដែលជ្រើសរើសចេញពីសិស្ស និស្សិត ត្រូវបានផ្តល់បៀវត្សមូលដ្ឋាននិងប្រាក់បំណាច់ផ្សេងៗ ដូចមានកំណត់ក្នុងសេចក្តីសម្រេចរួមស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ។

**មាត្រា ២៧.– ថ្មី**

អ្នករាជការណាដែលធ្វើការតទៅទៀតមិនបាន ដោយហេតុមកពីបាត់បង់សម្បទាវិជ្ជាជីវៈហើយដែលមិនបានបំពេញល័ក្ខខ័ណ្ឌគ្រប់គ្រាន់ដើម្បីទទួលសោធននិវត្តន៍ ត្រូវបានចាត់ទុកថា បាត់បង់សមត្ថភាពការងារ ហើយត្រូវបញ្ឈប់មិនឲ្យធ្វើការតទៅទៀត។

ក្នុងករណីនេះ សាមីជនត្រូវបានទទួលប្រាក់ធានារ៉ាប់រងសង្គមម្តងគត់ និងប្រាក់ដែលបានកាត់ទុកសម្រាប់សោធននិវត្តន៍។ បើអ្នករាជការនោះមានអតីតភាពការងារលើសពី ២០ ឆ្នាំ សាមីជនត្រូវបានតម្រូវឲ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ ដោយទទួលប្រាក់សោធននិវត្តន៍សមាមាត្រ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-អគ្គលេខាធិការ ឬតំណាង | ប្រធាន |
| ២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ | សមាជិក |
| ៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | សមាជិក |
| ៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ | សមាជិក |
| ៥-គ្រូពេទ្យដែលបានទទួលសច្ចាប្រណិធាន និងដែលត្រូវបានចាត់ឡើងដោយក្រសួងសុខាភិបាល | សមាជិក |
| ៦-អ្នករាជការដែលមានក្របខ័ណ្ឌជាមួយគ្នា ១ នាក់ ដែលមានឋានន្តរសក្តិយ៉ាងហោចណាស់ស្មើនឹងសាមីជន | សមាជិក ។ |

**មាត្រា ៣២.– ថ្មី**

នៅពេលតម្លើងថ្នាក់ដោយប្តូរឋានន្តរសក្តិ អ្នករាជការក្នុងថ្នាក់ខ្ពស់បំផុតនៃឋានន្តរសក្តិទី ៣ និងឋានន្តរសក្តិទី ២ នៃគ្រប់ក្របខ័ណ្ឌ ត្រូវបានតម្លើងឋានន្តរសក្តិទៅថ្នាក់ដំបូងនៃឋានន្តរសក្តិខ្ពស់បន្ទាប់ ។

## មាត្រា ៣៣.– ថ្មី

ការតម្លើងថ្នាក់ត្រូវកំណត់យក ៣ ភាគ ៤ (៣/៤) តាមវេនជ្រើសរើស និង ១ ភាគ ៤ (១/៤) តាមវេនអតីតភាពការងារ នៃគ្រប់ឋានន្តរសក្តិ និងគ្រប់ក្របខ័ណ្ឌ ។ លើសពីនេះ ការតម្លើងថ្នាក់ត្រូវធ្វើឡើងដោយការជ្រើសរើស ។

## មាត្រា ៣៤.– ថ្មី

អ្នករាជការក្របខ័ណ្ឌអភិបាលដែលមានសញ្ញាប័ត្រខ្ពស់ជាងបរិញ្ញាប័ត្រ ត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់ជាស្វ័យប្រវត្តិ។

អ្នករាជការក្របខ័ណ្ឌឧបការីដែលមានបរិញ្ញាប័ត្រ ឬសញ្ញាប័ត្រមានតម្លៃស្មើ ត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់ជាស្វ័យប្រវត្តិ ។

អ្នករាជការក្របខ័ណ្ឌលេខាធិការដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវបានតម្លើងថ្នាក់ ១ ថ្នាក់ជាស្វ័យប្រវត្តិ ។

អ្នករាជការដែលត្រូវបានតម្លើងថ្នាក់តាមសញ្ញាប័ត្រដូចមានចែងក្នុងកថាខ័ណ្ឌខាងលើ ត្រូវរក្សាទុកអតីតភាពសម្រាប់តម្លើងថ្នាក់ប្រចាំឆ្នាំតាមវេនជ្រើសរើស ឬតាមវេនអតីតភាព។

## មាត្រា ៣៥.– ថ្មី

ជារៀងរាល់ឆ្នាំនៅខែមករា នាយកដ្ឋានគ្រប់គ្រងបុគ្គលិកត្រូវចុះបញ្ជីអ្នករាជការដែលត្រូវពិនិត្យតម្លើងថ្នាក់ទាំងអស់ ហើយបញ្ជូនព្រឹត្តិប័ត្រពិន្ទុដល់អ្នករាជការទាំងអស់នោះឲ្យបំពេញ រួចបញ្ជូនទៅការិយាល័យ នាយកដ្ឋាន អគ្គនាយកដ្ឋាន ឬអង្គភាពសាមី ដើម្បីដាក់ពិន្ទុ និងចុះមូលវិចារណ៍ ។ បន្ទាប់ពីដាក់ពិន្ទុ និងចុះមូលវិចារណ៍រួចហើយ អគ្គនាយក ឬប្រធានអង្គភាពសាមី ត្រូវបញ្ជូនព្រឹត្តិប័ត្រពិន្ទុនោះទៅនាយកដ្ឋានគ្រប់គ្រងបុគ្គលិកវិញ ដើម្បីធ្វើបញ្ជីចំណាត់ថ្នាក់រួម ឬដោយឡែកតាមអគ្គនាយកដ្ឋាន ឬអង្គភាពសាមី ឬតាមក្របខ័ណ្ឌសម្រាប់រាយការណ៍ជូនគណៈកម្មការតម្លើងថ្នាក់នៅពេលប្រជុំ ។

រាល់ទំនាក់ទំនងការងារ និងការវាយតម្លៃខាងលើនេះ ត្រូវធ្វើដោយសម្ងាត់ ។

## មាត្រា ៣៦.– ថ្មី

អគ្គលេខាធិការបញ្ឈប់បញ្ជីអ្នករាជការដែលត្រូវបានស្នើពិនិត្យតម្លើងថ្នាក់រួចបញ្ជូនទៅគណៈកម្មការតម្លើងថ្នាក់ដើម្បីធ្វើការប្រជុំ ។

សមាសភាពគណៈកម្មការតម្លើងថ្នាក់មានដូចតទៅ ៖

១-អគ្គលេខាធិការ ឬតំណាង ប្រធាន

២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ សមាជិក

៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក សមាជិក

៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យពាក់ព័ន្ធ សមាជិក

៥-អ្នករាជការដែលមានក្របខ័ណ្ឌជាមួយគ្នា ២ នាក់ សមាជិក ។

## មាត្រា ៥៦.- ថ្មី

ត្រូវបានបង្កើតក្រុមប្រឹក្សាវិន័យដែលមានសមាសភាព ៖

១-អគ្គលេខាធិការ ឬតំណាង ប្រធាន

២-អគ្គនាយក ឬ/និងប្រធានអង្គភាពពាក់ព័ន្ធ សមាជិក

៣-ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក សមាជិក

៤-ប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យនៃអ្នករាជការជាប់ចោទ សមាជិក

៥-អ្នករាជការចំនួន ២ ឬ ៣ នាក់ ដែលមានក្របខ័ណ្ឌដូចគ្នាតែមាន អតីតភាពការងារច្រើនជាង សមាជិក ។

មិនអាចចាត់ឲ្យចូលក្នុងក្រុមប្រឹក្សាវិន័យនេះបាន អ្នករាជការណាដែលជាអ្នកធ្វើសេចក្តីរាយការណ៍ ឬពាក្យបណ្តឹងចំពោះអ្នករាជការជាប់ចោទ ឬសាច់ញាតិរហូតដល់ថ្នាក់ទី ៣ នៃអ្នករាជការជាប់ចោទ ។

## មាត្រា ៦៥.- ថ្មី

អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិត្រូវបានដាក់ឲ្យចូលនិវត្តន៍តាមល័ក្ខខ័ណ្ឌអាយុដូចខាងក្រោម ៖

-៦០ ឆ្នាំ សម្រាប់ក្របខ័ណ្ឌអភិបាល (ប្រភេទ ក)

-៥៨ ឆ្នាំ សម្រាប់ក្របខ័ណ្ឌឧបការី (ប្រភេទ ខ)

-៥៥ ឆ្នាំ សម្រាប់ក្របខ័ណ្ឌលេខាធិការ (ប្រភេទ គ ) ។

អ្នករាជការក្របខ័ណ្ឌអភិបាល ក្របខ័ណ្ឌឧបការី និងក្របខ័ណ្ឌលេខាធិការ ដែលដល់អាយុចូលនិវត្តន៍ អាចអនុញ្ញាតឲ្យបន្តការងារបានតាមសេចក្តីស្នើរបស់សាមីខ្លួន និងតាមសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន។ ការបន្តការងារនេះមានរយៈពេល ១ ឆ្នាំម្តង ប៉ុន្តែមិនឲ្យលើសពីបីដងឡើយ ។

គោលការណ៍ និងនីតិវិធីនៃការដាក់ឲ្យអ្នករាជការចូលនិវត្តន៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

## មាត្រា ៧៣.- ថ្មី

គោលការណ៍ និងល័ក្ខខ័ណ្ឌនៃការធ្វើសមាហរណកម្មក្របខ័ណ្ឌបច្ចុប្បន្នរបស់អ្នករាជការនៃក្រុមនីតិប្បញ្ញត្តិ ទៅក្នុងប្រភេទក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ថ្មី ត្រូវកំណត់ដោយសេចក្តីសម្រេចរួមរបស់ប្រធានស្ថាប័នទាំងបី ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

បែបបទ និងនីតិវិធីនៃការធ្វើសមាហរណកម្មអ្នករាជការនៃក្រុមនីតិប្បញ្ញត្តិ ទៅក្នុងប្រភេទ ក្របខណ្ឌ ឋានន្តរសក្តិ និងថ្នាក់ថ្មី ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានស្ថាប័ន ។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកម.០៤១៧/០០៧

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៤០២ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**